**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ ២០០.អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## លក្ខខណ្ឌនិងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខនស/រកម/១២០៦/០៣០ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកាតព្វកិច្ចយោធា
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខខណ្ឌ និងបែបបទនៃការធ្វើជំរឿន ការជ្រើសរើស ការអញ្ជើញ ការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងករណីពិសេស និងការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ ៖

- ការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ
- ចូលរួមកែទម្រង់វិស័យកងទ័ព
- ពង្រឹងមូលដ្ឋានគ្រឹះនៃប្រភពកសាងកម្លាំងសម្រាប់វិស័យការពារជាតិ និងការអភិវឌ្ឍកាយសម្បទា ដែលជាតម្រូវការរបស់ប្រទេសជាតិ
- បណ្តុះបណ្តាលជំនាញការពារជាតិ ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់ លើប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុចាប់ពី១៨(ដប់ប្រាំបី) ឆ្នាំ ដល់៣០ (សាមសិប) ឆ្នាំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការបំពេញកាតព្វកិច្ចយោធារបស់ប្រជាពលរដ្ឋខ្មែរ ជាស្ត្រីភេទគ្រប់រូប ត្រូវផ្អែកតាមការស្ម័គ្រចិត្ត ។

**មាត្រា៤.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលប្រើក្នុងអនុក្រឹត្យនេះ សំដៅដល់ប្រជាពលរដ្ឋខ្មែរជាជនស៊ីវិលធម្មតា កម្មករ និយោជិត និយោជក សិស្ស និស្សិត មន្ត្រីរាជការស៊ីវិល និងប្រជាពលរដ្ឋខ្មែរដែលមានសញ្ជាតិពីរ ហើយរស់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២

## សមត្ថកិច្ចនិងយន្តការ

### ផ្នែកទី១

### គណៈកម្មាធិការជាតិកាតព្វកិច្ចយោធា

**មាត្រា៥.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិកាតព្វកិច្ចយោធា ហៅកាត់ថា **គ.ជ.ក.** ដែលមានសមាសភាពដូចតទៅ ៖

- រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធាន
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋលេខាធិការមួយរូប អនុប្រធាន
- អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬរដ្ឋលេខាធិការមួយរូប សមាជិក
- រដ្ឋមន្ត្រីក្រសួងផែនការ ឬរដ្ឋលេខាធិការមួយរូប សមាជិក
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬរដ្ឋលេខាធិការមួយរូប សមាជិក
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬរដ្ឋលេខាធិការមួយរូប សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬរដ្ឋលេខាធិការមួយរូប សមាជិក
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬរដ្ឋលេខាធិការមួយរូប សមាជិក
- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សមាជិក
- អគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ សមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- នាយក នាយកដ្ឋានបុគ្គលិកនៃក្រសួងការពារជាតិ លេខាធិការ ។

សមាសភាពជាក់ស្តែងនៃ **គ.ជ.ក.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា៦.-**

**គ.ជ.ក.** មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយជាតិកាតព្វកិច្ចយោធា
- អនុវត្តអនុក្រឹត្យស្តីពីចំនួនប្រជាពលរដ្ឋ និងលក្ខខណ្ឌទាំងឡាយ ក្នុងការចូលបំពេញកាតព្វកិច្ចយោធាសម្រាប់វគ្គនីមួយៗរៀងរាល់ឆ្នាំតាមសំណើរបស់ក្រសួងការពារជាតិនិងលិខិតបទដ្ឋានទាក់ទងនឹងកាតព្វកិច្ចយោធា
- រៀបចំទម្រង់បែបបទគំរូ ខ្លឹមសារសេចក្តីសម្រេច សេចក្តីណែនាំ និងវិធាននានាក្នុងដំណើរការអនុវត្តច្បាប់ស្តីពីកាតព្វកិច្ចយោធា
- ដឹកនាំ និងត្រួតពិនិត្យដំណើរការនៃការអនុវត្តកាតព្វកិច្ចយោធា
- តែងតាំងសមាសភាពគណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ខេត្ត
- បង្កើតគណៈកម្មការសុខាភិបាល សម្រាប់ត្រួតពិនិត្យសុខភាព នៅនឹងកន្លែងជ្រើសរើស
- ធ្វើរបាយការណ៍អំពីលទ្ធផលកាតព្វកិច្ចយោធាជូនរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

**មាត្រា៧.-**

**គ.ជ.ក.** មានសិទ្ធិបង្កើតក្រុមការងារតាមតម្រូវការចាំបាច់ ។

ប្រធាន **គ.ជ.ក.** មានសិទ្ធិអញ្ជើញតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់ ។

មាត្រា៨.-

គ.ជ.ក. មានសិទ្ធិប្រើប្រាស់ត្រាក្រសួងការពារជាតិ ។

គ.ជ.ក. មាននាយកដ្ឋានបុគ្គលិកនៃក្រសួងការពារជាតិ ជាលេខាធិការដ្ឋាន ។

## ផ្នែកទី២

## គណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ខេត្ត

មាត្រា៩.-

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធារាជធានី ខេត្ត ហៅកាត់ថា គ.ក.រ.ខ. ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - មេបញ្ជាការរងយោធភូមិភាគ មួយរូប | អនុប្រធាន |
| - មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ឬមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| - ស្នងការនគរបាលរាជធានី ខេត្ត | សមាជិក |
| - មេបញ្ជាការកងរាជអាវុធហត្ថខេត្ត | សមាជិក |
| - ប្រធានមន្ទីរផែនការរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត | សមាជិក |
| - អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌចំណុះរាជធានី ខេត្ត | សមាជិក ។ |

សមាសភាពជាក់ស្តែងនៃ គ.ក.រ.ខ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ក. ។

មាត្រា១០.-

គ.ក.រ.ខ. មានតួនាទីនិងភារកិច្ច ដូចតទៅ ៖

- ចាត់ចែង និងអនុវត្តគោលនយោបាយកាតព្វកិច្ចយោធា
- ដឹកនាំការធ្វើជំរឿនកាតព្វកិច្ចយោធា
- ដឹកនាំការជ្រើសរើស និងពិនិត្យកាយសម្បទា និងសុខភាពប្រជាពលរដ្ឋចូលបំពេញកាតព្វកិច្ចយោធា
- សម្រេចសមាសភាពប្រជាពលរដ្ឋ ដែលត្រូវអញ្ជើញចូលបំពេញកាតព្វកិច្ចយោធា
- សម្រេចអនុញ្ញាតចំពោះសមាសភាពប្រជាពលរដ្ឋ សុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា

និងសមាសភាពប្រជាពលរដ្ឋ មិនត្រូវចូលបំពេញកាតព្វកិច្ចយោធា

- ដឹកនាំការធានាសុវត្ថិភាពដល់ដំណើរការជ្រើសរើសប្រជាពលរដ្ឋ ចូលបំពេញកាតព្វកិច្ចយោធា ទូទាំងរាជធានី ខេត្តរបស់ខ្លួន
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលនៃដំណើរការការងាររបស់ខ្លួនជូន គ.ជ.ក.
- បំពេញភារកិច្ចផ្សេងៗទៀតដែល គ.ជ.ក. ប្រគល់ជូន ។

**មាត្រា១១.-**

គ.ក.រ.ខ. មានកងរាជអាវុធហត្ថរាជធានី ឬតំបន់ប្រតិបត្តិការសឹករងខេត្ត ជាសេនាធិការ ។

គ.ក.រ.ខ. មានសិទ្ធិប្រើប្រាស់ត្រារដ្ឋបាលរាជធានី ខេត្ត ។

**មាត្រា១២.-**

គ.ក.រ.ខ. មានសិទ្ធិបង្កើតក្រុមការងារតាមតម្រូវការចាំបាច់ ។

## ផ្នែកទី៣

## គណៈកម្មាធិការកាតព្វកិច្ចយោធាមូលដ្ឋានឃុំ សង្កាត់

**មាត្រា១៣.-**

ត្រូវបានបង្កើតគណៈកម្មាធិការកាតព្វកិច្ចយោធាមូលដ្ឋានឃុំ សង្កាត់ ហៅកាត់ថា គ.ក.ឃ.ស. ដែលមានសមាសភាព ដូចតទៅ ៖

| | |
|---|---|
| - អភិបាល ឬអភិបាលរងនៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ មួយរូប | ប្រធាន |
| - មេឃុំ ចៅសង្កាត់ | អនុប្រធានអចិន្ត្រៃយ៍ |
| - មន្ត្រីយោធាទទួលបន្ទុកកិច្ចការកាតព្វកិច្ចយោធា មួយរូប | អនុប្រធាន |
| - មន្ត្រីនគរបាលក្រុង ស្រុក ខណ្ឌ មួយរូប | អនុប្រធាន |
| - មន្ត្រីកងរាជអាវុធហត្ថ មួយរូប | សមាជិក |
| - មន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មួយរូប | សមាជិក |
| - មន្ត្រីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មួយរូប | សមាជិក |
| - នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ | សមាជិក |
| - ស្មៀនឃុំ សង្កាត់ | សមាជិក ។ |

សមាសភាពជាក់ស្តែងនៃ គ.ក.ឃ.ស. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ក.រ.ខ.

**មាត្រា១៤.–**

**គ.ក.ឃ.ស.** មានតួនាទីនិងភារកិច្ច ដូចតទៅ ៖

- ទទួលខុសត្រូវក្នុងការធ្វើស្ថិតិ ការចុះបញ្ជីជំរឿនកាតព្វកិច្ចយោធា
- ចាត់ចែងការជ្រើសរើស ត្រួតពិនិត្យកាយសម្បទា និងសុខភាពដោយសហការជាមួយគណៈកម្មការសុខាភិបាល
- ធ្វើរបាយការណ៍ជាប្រចាំអំពីលទ្ធផលដំណើរការការងាររបស់ខ្លួនជូន **គ.ក.រ.ខ.**
- ជូនដំណឹងដល់សាមីជនដែលត្រូវបានជ្រើសរើសចូលបំពេញកាតព្វកិច្ចយោធា សាមីជនដែលត្រូវបានយល់ព្រមឱ្យពន្យារពេល
- បំពេញភារកិច្ចផ្សេងៗទៀតដែល **គ.ក.រ.ខ.** ប្រគល់ជូន ។

**មាត្រា១៥.–**

**គ.ក.ឃ.ស.** មានសាលាឃុំ សង្កាត់ ជាលេខាធិការ ។

**គ.ក.ឃ.ស.** មានសិទ្ធិប្រើប្រាស់ត្រារដ្ឋបាលក្រុង ស្រុក ខណ្ឌ ។

## ជំពូកទី៣
## ការធ្វើជំរឿន

**មាត្រា១៦.–**

ការធ្វើបញ្ជីជំរឿនកាតព្វកិច្ចយោធា ត្រូវប្រព្រឹត្តទៅពីដើមខែមករា រហូតដល់ដំណាច់ខែមីនា ជារៀងរាល់ឆ្នាំ ដោយ **គ.ក.ឃ.ស.** ។

**មាត្រា១៧.–**

ការធ្វើបញ្ជីជំរឿនកាតព្វកិច្ចយោធា ត្រូវផ្អែកលើឯកសារណាមួយក្នុងចំណោមឯកសារដូចខាងក្រោម ៖

- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- សំបុត្រកំណើត
- ឯកសារផ្សេងៗដែលបញ្ជាក់សញ្ជាតិខ្មែរ ។

សាមីខ្លួនត្រូវទៅចុះឈ្មោះដោយផ្ទាល់ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលជាអ្នកទៅចុះឈ្មោះជំនួស ។

ប្រជាពលរដ្ឋដែលបានទៅចុះឈ្មោះក្នុងបញ្ជីជំរឿន ត្រូវទទួលបានបណ្ណជំរឿនកាតព្វកិច្ចយោធា ។

**មាត្រា១៨.–**

ការធ្វើជំរឿនកាតព្វកិច្ចយោធា ត្រូវធ្វើចំពោះប្រជាពលរដ្ឋខ្មែរគ្រប់រូបលើកលែងតែ ៖

- ប្រជាពលរដ្ឋដែលបានបញ្ចប់សេវាជាយោធិនជាប់កិច្ចសន្យា
- ប្រជាពលរដ្ឋដែលកំពុងបម្រើការងារជាប្រយោជន៍សាធារណៈ ក្នុងកងយោធពលខេមរភូមិន្ទ ដែលមានថ្ងៃ

ក្នុងមាត្រា៣៥ នៃអនុក្រឹត្យនេះ
- ព្រះសង្ឃ បព្វជិតនៃសាសនាផ្សេងៗដែលមានការទទួលស្គាល់ពីក្រសួងធម្មការ និងសាសនា
- ប្រជាពលរដ្ឋពិការ
- ជនដែលកំពុងស្ថិតក្នុងពន្ធនាគារ ។

**មាត្រា១៩.-**

ពេលផ្លាស់ប្តូរទីលំនៅ ឬផ្លាស់ប្តូរអង្គភាព ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីជំរឿនកាតព្វកិច្ចយោធា ត្រូវរាយការណ៍ជូន **គ.ក.ឃ.ស.** ក្នុងឃុំ សង្កាត់ចាស់ដែលខ្លួនស្នាក់នៅ ហើយក្នុងរយៈពេលយ៉ាងយូរ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលទៅដល់ក្នុងឃុំ សង្កាត់ថ្មី សាមីខ្លួនត្រូវទៅសុំចុះឈ្មោះក្នុងបញ្ជីជំរឿនកាតព្វកិច្ចយោធារបស់ **គ.ក.ឃ.ស.** ក្នុងឃុំ សង្កាត់ថ្មីដែលខ្លួនរស់នៅ ។

**មាត្រា២០.-**

រៀងរាល់ឆ្នាំនៅដើមខែមករា ស្ថាប័នរដ្ឋ គ្រឹះស្ថានសិក្សា រោងចក្រ សហគ្រាស អង្គការ សមាគមនានា ត្រូវស្រង់ស្ថិតិ និងធ្វើបញ្ជីឈ្មោះមន្ត្រីបុគ្គលិកទាំងអស់ ដែលមានអាយុត្រូវចូលបំពេញកាតព្វកិច្ចយោធា ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនជូនដល់ **គ.ក.ឃ.ស.** នៅក្នុងមូលដ្ឋានឃុំ សង្កាត់ ដែលអង្គភាពរបស់ខ្លួនតាំងនៅ ព្រមទាំងក្រើនរំលឹកមន្ត្រីបុគ្គលិកក្រោមឱវាទឱ្យទៅចុះឈ្មោះក្នុង បញ្ជីជំរឿនកាតព្វកិច្ចយោធាឱ្យបានគ្រប់ៗគ្នា ។

អ្នកដែលបានចុះឈ្មោះក្នុងបញ្ជីជំរឿនរួចហើយ ត្រូវយកបណ្ណជំរឿនកាតព្វកិច្ចយោធាទៅបង្ហាញប្រធានអង្គភាព ឬស្ថាប័នរបស់ខ្លួន ។

## ជំពូកទី៤
## ការជ្រើសរើស

**មាត្រា២១.-**

នៅដើមខែសីហារៀងរាល់ឆ្នាំ **គ.ក.ឃ.ស.** ត្រូវចេញលិខិតអញ្ជើញប្រជាពលរដ្ឋ ដែលមានឈ្មោះក្នុងបញ្ជីជំរឿន ហើយរស់នៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីចូលរួមក្នុងការជ្រើសរើស និងពិនិត្យសុខភាពត្រៀមចូលបំពេញកាតព្វកិច្ចយោធា ។

**មាត្រា២២.-**

លក្ខណសម្បត្តិប្រជាពលរដ្ឋដែលត្រូវជ្រើសរើសឱ្យចូលបំពេញកាតព្វកិច្ចយោធា គឺមានកាយសម្បទា និងសុខភាពល្អ តាមការកំណត់ ។

ការពិនិត្យជ្រើសរើសត្រូវបែងចែកជាបីប្រភេទ ៖

- ប្រភេទទី១ គឺប្រជាពលរដ្ឋដែលមានកាយសម្បទា និងសុខភាពល្អគ្រប់គ្រាន់
- ប្រភេទទី២ គឺប្រជាពលរដ្ឋដែលមានកាយសម្បទា និងសុខភាពមធ្យម ដាក់ជាបម្រុងសម្រាប់ការជ្រើសរើស បំពេញបន្ថែម នៅពេលដែលប្រជាពលរដ្ឋប្រភេទទី១មិនគ្រប់តាមតម្រូវការ

- ប្រភេទទី៣ គឺប្រជាពលរដ្ឋដែលមានកាយសម្បទាមិនប្រក្រតី មិនគ្រប់ខ្នាត ឬមានជំងឺមិនអាចចូលបំពេញកាតព្វកិច្ចយោធាបាន ។

ការរៀបរាប់លម្អិតអំពីលក្ខខណ្ឌកាយសម្បទា និងសុខភាពប្រជាពលរដ្ឋប្រភេទទី១ ទី២ និងទី៣ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា២៣.-**

ប្រជាពលរដ្ឋត្រូវទទួលបានបណ្ណកាយសម្បទា និងសុខភាពកាតព្វកិច្ចយោធា តាមកម្រិតប្រភេទជាក់ស្តែងសម្រាប់សាមីខ្លួនម្នាក់ៗ ក្រោយពេលពិនិត្យកាយសម្បទា និងសុខភាពដោយ **គ.ភ.ឃ.ស.** និងគណៈកម្មការសុខាភិបាលពិនិត្យនៅនឹងកន្លែងរួចហើយ ។

**មាត្រា២៤.-**

ប្រធាន **គ.ភ.ឃ.ស.** ត្រូវរាយការណ៍លទ្ធផលជ្រើសរើសជាបន្ទាន់ជូនដល់ **គ.ភ.រ.ខ.** ។

ក្នុងករណីមានបញ្ហាមិនប្រក្រតី ប្រធាន **គ.ភ.ឃ.ស.** ត្រូវស្នើសុំមតិពី **គ.ភ.រ.ខ.** ។

**មាត្រា២៥.-**

**គ.ភ.ឃ.ស.** ត្រូវរៀបចំការិយាល័យជ្រើសរើសនៅទីកន្លែងមួយជាសាធារណៈ ។ ក្នុងករណីដែលប្រធានសក្តិកើតឡើងចំថ្ងៃជ្រើសរើស **គ.ភ.ឃ.ស.** មានសិទ្ធិផ្អាកការជ្រើសរើសជាបណ្តោះអាសន្ន ហើយត្រូវរាយការណ៍ជាបន្ទាន់ជូនដល់ **គ.ភ.រ.ខ.** និងរាយការណ៍តាមឋានានុក្រមជូនដល់រាជរដ្ឋាភិបាល ។

## ជំពូកទី៥

## លក្ខខណ្ឌនៃការពន្យារពេលសម្រាប់យុវជនកំពុងជាប់ការសិក្សា

**មាត្រា២៦.-**

សិស្ស និស្សិតដែលទទួលបានការអនុញ្ញាតតាមការស្នើសុំរបស់ខ្លួន ឱ្យពន្យារពេលចូលបំពេញកាតព្វកិច្ចយោធារួមមាន ៖

- និស្សិតដែលកំពុងជាប់កម្មសិក្សា ឬស្រាវជ្រាវបញ្ចប់វគ្គជំនាញ ឬឯកទេស
- សិស្ស និស្សិតថ្នាក់ត្រៀមប្រឡង បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ បរិញ្ញាបត្ររងមធ្យមសិក្សាបត្រទុតិយភូមិ ឬមធ្យមសិក្សាបត្របឋមភូមិ
- សិស្ស និស្សិតជាប់អាហារូបករណ៍ទៅរៀនក្រៅប្រទេស
- សិស្ស និស្សិតត្រូវទៅបន្តការសិក្សានៅក្រៅប្រទេស ។

**មាត្រា២៧.-**

សិស្ស និស្សិតដែលសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធាត្រូវដាក់ជូន **គ.ភ.ឃ.ស.** នូវពាក្យសុំពន្យារពេលរបស់ខ្លួនដោយបញ្ជាក់មូលហេតុ និងមានការបញ្ជាក់ពីប្រធានគ្រឹះស្ថានសិក្សា ។

ការសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវបានទទួលស្គាល់ថាមានការអនុញ្ញាតជាផ្លូវការ លុះត្រាតែមានលិខិតជូនដំណឹងពី **គ.ភ.ឃ.ស.** យោងតាមសេចក្តីសម្រេចឯកភាពពី **គ.ភ.រ.ខ.**។ **គ.ភ.ឃ.ស.** ត្រូវដកហូតបណ្ណកាយសម្បទា និងសុខភាពកាតព្វកិច្ចយោធា ទុកដើម្បីធ្វើការពិនិត្យឡើងវិញនៅពេលអញ្ជើញលើកក្រោយ។

ការឆ្លើយតបចំពោះសិស្ស និស្សិតដែលបានដាក់ពាក្យសុំពន្យារពេល ត្រូវធ្វើក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ យ៉ាងយូរក្រោយពេលទទួលពាក្យសុំរបស់សាមីខ្លួន។

រាល់ការពន្យារពេលត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំដោយ **គ.ភ.ឃ.ស.**។

## ជំពូកទី៦

## លក្ខខណ្ឌនៃការពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា សម្រាប់ប្រជាពលរដ្ឋដែលស្ថិតក្នុងករណីពិសេស

**មាត្រា២៨.-**

ប្រជាពលរដ្ឋដែលត្រូវបានអនុញ្ញាតឱ្យពន្យារពេលចូលបំពេញកាតព្វកិច្ចយោធារួមមាន ៖

- ប្រជាពលរដ្ឋដែលជាកម្លាំងពលកម្មតែម្នាក់ឯងគត់ក្នុងគ្រួសារ ហើយទទួលបន្ទុកចិញ្ចឹមមនុស្ស ដែលមិនទាន់ដល់អាយុពេញពលកម្ម ឬចាស់ជរា ឬពិការច្រើននាក់
- ប្រជាពលរដ្ឋជាកូនកំព្រាតែម្នាក់គត់ដែលឪពុក ឬម្តាយបានពលីក្នុងសមរភូមិ
- ប្រជាពលរដ្ឋជាកូនទោលក្នុងគ្រួសារដែលមានតែម្តាយនិងកូន ឬឪពុកនិងកូន
- ប្រជាពលរដ្ឋពោះម៉ាយ ដែលមានកូនច្រើននាក់នៅក្នុងបន្ទុក
- ប្រជាពលរដ្ឋដែលកំពុងសម្រាកព្យាបាលជំងឺ
- ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងស្ថានភាពរងគ្រោះ ក្នុងករណីប្រធានសក្តិ និងគ្រោះធម្មជាតិ
- ប្រជាពលរដ្ឋដែលត្រូវទៅរស់នៅជាមួយឪពុកម្តាយ ដែលបំពេញបេសកកម្មរយៈពេលវែង នៅក្រៅប្រទេស
- មន្ត្រីរាជការដែលត្រូវទៅបំពេញការងារនៅបរទេសមានរយៈពេលចាប់ពី៣ (បី) ខែឡើង
- សាស្ត្រាចារ្យ គ្រូបង្រៀនក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា
- កម្មករដែលជាអ្នកជំនាញឯកទេសក្នុងរោងចក្រ សហគ្រាស ហើយដែលមិនអាចរកអ្នកជំនួសបានភ្លាមៗ
- និយោជកដែលទទួលបន្ទុកដឹកនាំការងារជំនាញ ឬឯកទេសក្នុងសហគ្រាស ហើយដែលមិនអាចរកអ្នកជំនួសបានភ្លាមៗ។

**មាត្រា២៩.-**

ប្រជាពលរដ្ឋដែលសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវដាក់ជូន **គ.ភ.ឃ.ស.** នូវពាក្យសុំពន្យារពេលរបស់ខ្លួន ដោយបញ្ជាក់មូលហេតុ និងមានការបញ្ជាក់ពីអាជ្ញាធរឃុំ សង្កាត់។

មន្ត្រីរាជការដែលជាប់បេសកកម្មទៅបំពេញភារកិច្ចនៅក្រៅប្រទេស ត្រូវដាក់ជូន **គ.ភ.ឃ.ស.** នូវពាក្យសុំ

ពន្យារពេលរបស់ខ្លួនដោយបញ្ជាក់មូលហេតុ និងមានការបញ្ជាក់ពីក្រសួង ស្ថាប័នសាមី ។

និយោជក កម្មករ និយោជិតដែលសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវដាក់ជូន **គ.ក.ឃ.ស.** នូវពាក្យសុំពន្យារពេលរបស់ខ្លួន ដោយមានការបញ្ជាក់ពីប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ។

**មាត្រា៣០.-**

ការសុំពន្យារពេលចូលបំពេញកាតព្វកិច្ចយោធា ត្រូវបានទទួលស្គាល់ថា បានការអនុញ្ញាតជាផ្លូវការ លុះត្រាតែបានទទួលលិខិតជូនដំណឹងពី **គ.ក.ឃ.ស.** យោងតាមសេចក្តីសម្រេចឯកភាពរបស់ **គ.ក.រ.ខ.** ។

ការឆ្លើយតបចំពោះប្រជាពលរដ្ឋស្ថិតក្នុងករណីពិសេស ដែលបានដាក់ពាក្យសុំពន្យារពេល ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ យ៉ាងយូរក្រោយពេលបានទទួលពាក្យសុំ របស់សាមីខ្លួន ។

រាល់ការពន្យារពេលត្រូវពិនិត្យឡើងវិញរៀងរាល់ឆ្នាំដោយ **គ.ក.ឃ.ស.** ។

**គ.ក.ឃ.ស.** ត្រូវដកហូតបណ្ណកាយសម្បទា និងសុខភាពកាតព្វកិច្ចយោធា ទុកដើម្បីធ្វើការអញ្ជើញនៅលើកក្រោយ ។

## ជំពូកទី៧

## ការអញ្ជើញចូលបំពេញកាតព្វកិច្ចយោធា

**មាត្រា៣១.-**

ការសម្រេចទទួលឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវ ៖

- ទទួលយកមុនគេប្រជាពលរដ្ឋដែលស្នើសុំចូលបំពេញកាតព្វកិច្ចយោធា
- ធ្វើការចាប់ឆ្នោតនៅពេលប្រជាពលរដ្ឋដែលស្នើសុំចូលបំពេញកាតព្វកិច្ចយោធា មានចំនួនច្រើន ឬតិចជាងតម្រូវការ ។

**មាត្រា៣២.-**

**គ.ក.រ.ខ.** ត្រូវចេញសេចក្តីសម្រេចអញ្ជើញប្រជាពលរដ្ឋឱ្យចូលបំពេញកាតព្វកិច្ចយោធា តាមចំនួនតម្រូវការប្រចាំឆ្នាំ ។

**គ.ក.ឃ.ស.** ត្រូវជូនសេចក្តីសម្រេចអញ្ជើញប្រជាពលរដ្ឋឱ្យចូលបំពេញកាតព្វកិច្ចយោធាដល់សាមីខ្លួន ដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរឃុំ សង្កាត់ ឬប្រធានអង្គភាព ក្រសួង មន្ទីរ រោងចក្រ សហគ្រាស ឬគ្រឹះស្ថានសិក្សា ក្នុងរយៈពេលយ៉ាងតិច៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃកំណត់ចូលបង្ហាញខ្លួន ។

**មាត្រា៣៣.-**

ប្រជាពលរដ្ឋដែលមានឈ្មោះអញ្ជើញឱ្យចូលបំពេញកាតព្វកិច្ចយោធា ត្រូវមកបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែង ដែលកំណត់ក្នុងសេចក្តីសម្រេចអញ្ជើញ ។

ប្រជាពលរដ្ឋដែលត្រូវមកបង្ហាញខ្លួន ត្រូវយកមកជាមួយនូវឯកសារមួយចំនួនដូចជា ៖

- សេចក្តីសម្រេចអញ្ជើញប្រជាពលរដ្ឋឱ្យចូលបំពេញកាតព្វកិច្ចយោធា
- វិញ្ញាបនបត្រសិក្សា វិញ្ញាបនបត្រឯកទេស ឬសញ្ញាបត្រផ្សេងៗទៀត ប្រសិនបើមាន
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណបណ្ណសិស្ស និស្សិត ។

## ជំពូកទី៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា៣៤.-**

ក្រសួងការពារជាតិ ត្រូវចេញបណ្ណបំពេញកាតព្វកិច្ចយោធាឱ្យប្រជាពលរដ្ឋ ដែលបានបញ្ចប់កាតព្វកិច្ចយោធា និងប្រជាពលរដ្ឋដែលបានបំពេញបេសកកម្ម ជាប្រយោជន៍សាធារណៈ ក្នុងកងយោធពលខេមរភូមិន្ទ ក្នុងរយៈពេលគ្រប់១៨ (ដប់ប្រាំបី) ខែ។

**មាត្រា៣៥.-**

អ្នកឯកទេសជំនាញវិជ្ជាជីវៈដែលមានបំណងចុះកិច្ចសហប្រតិបត្តិការបំពេញបេសកកម្ម ស្រាវជ្រាវ ឬអនុវត្តផ្ទាល់នូវកិច្ចការដែលជាប្រយោជន៍សាធារណៈនៃកងយោធពលខេមរភូមិន្ទ ដែលមានរយៈពេលស្មើនឹងស្ថានភាពកាតព្វកិច្ចយោធាចំនួន១៨ (ដប់ប្រាំបី) ខែ ដើម្បីរួចផុតពីកាតព្វកិច្ចយោធា ត្រូវដាក់ពាក្យនៅក្រសួងការពារជាតិ។

កិច្ចការនៃអ្នកឯកទេសជំនាញវិជ្ជាជីវៈទាំងនោះរួមមានសេវា ៖

- ផ្នែកវិស្វកម្ម ស្ពានថ្នល់ និងសំណង់
- ផ្នែកបោសសំអាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ
- ផ្នែកសុខាភិបាល
- ផ្នែកទូរគមនាគមន៍
- ផ្នែកព័ត៌មានវិទ្យា។

**មាត្រា៣៦.-**

ការគ្រប់គ្រង ការចាត់តាំង ការហ្វឹកហ្វឺន ការធានាជីវភាពយោធិនបំពេញកាតព្វកិច្ចយោធា និងការអនុញ្ញាតឱ្យវិលត្រឡប់ទៅកាន់ភាពស៊ីវិលវិញ នៃប្រជាពលរដ្ឋដែលបានបំពេញកាតព្វកិច្ចយោធាចប់ ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ និងអគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ។

ការហ្វឹកហ្វឺនបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាទិភាពក្នុងការរកការងារឱ្យធ្វើសម្រាប់ប្រជាពលរដ្ឋ ដែលបានបំពេញកាតព្វកិច្ចយោធា និង/ឬការបញ្ចូលទៅក្នុងក្របខណ្ឌដើមរបស់ក្រសួង មន្ទីរ សហគ្រាស ឬក្រុមហ៊ុននានា [illegible]

របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង/ឬ ស្ថាប័នដើម ឬអង្គភាពដើមរបស់សាមីខ្លួន និង/ឬ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**មាត្រា៣៧.-**

ធនធានសម្រាប់ធានារាល់ការចំណាយ ក្នុងការអនុវត្តកាតព្វកិច្ចយោធា គឺត្រូវបញ្ចូលក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងការពារជាតិ ។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ